**គណៈកម្មការទន្លេមេគង្គ**

ការិយាល័យលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនៅភ្នំពេញ
ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម
ប្រអប់សំបុត្រលេខ ៦២៣ ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៤២៥ ៣៥៣
ទូរសារលេខ: ៨៥៥-២៣ ៤២៥ ៣៦៣

ការិយាល័យលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនៅវៀងច័ន្ទ
ការិយាល័យប្រធានលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គ
អាគារលេខ ១៨៤ ផ្លូវ ហ្វា ងុម
ប្រអប់សំបុត្រលេខ ៦១០១ ទីក្រុងវៀងច័ន្ទ
សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
ទូរស័ព្ទលេខ: ៨៥៦-២១ ២៦៣ ២៦៣
ទូរសារលេខ: ៨៥៦-២១ ២៦៣ ២៦៤

## ពត៌មានសំរាប់ប្រព័ន្ធផ្សព្វផ្សាយ

*ថ្ងៃទី ១៩ មេសា ឆ្នាំ ២០១១*

# ប្រទេសមេគង្គក្រោមនឹងនាំយកការពិគ្រោះយោបល់ជាមុនស្តីពីគំរោងសាយ៉ាប៊ូរី ទៅថ្នាក់រដ្ឋមន្ត្រី

**សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ទទូចថាដំណើរការត្រូវបញ្ចប់ ខណៈប្រទេសមេគង្គដទៃទៀត លើកពីកង្វល់ចំពោះផលប៉ះពាល់ និងកង្វះខាតផ្នែកចំណេះដឹងខាងបច្ចេកទេស ព្រមទាំងវិធានការណ៍កាត់បន្ថយផលប៉ះពាល់**

**ទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ –** ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានឯកភាពគ្នានៅថ្ងៃនេះថា សេចក្តីសំរេចលើដំណើរការនៃការពិគ្រោះយោបល់ជាមុនអំពីសំណើគំរោងវារីអគ្គិសនីសាយ៉ាប៊ូរី នឹងត្រូវលើកយកទៅពិចារណានៅថ្នាក់រដ្ឋមន្ត្រី ដោយហេតុថាពួកគេពុំអាចធ្វើសេចក្តីសំរេចរួមថាត្រូវដំណើរការគំរោង រឺយ៉ាងណា ។

សមាជិកទាំងបួននៃគណៈកម្មការទន្លេមេគង្គ បានធ្វើសេចក្តីសំរេចក្នុងកិច្ចប្រជុំពិសេសនៃគណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គនៅទីក្រុងវៀងច័ន្ទ ក្នុងពេលដែលប្រទេសទាំងបួនជួបជុំដើម្បីពិភាក្សាលើសំណើគំរោងវារីអគ្គិសនីសាយ៉ាប៊ូរី ដែលជាគំរោងទីមួយនៅលើទន្លេមេ នៃអាងទន្លេមេគង្គក្រោម ។

សមាជិកគណៈកម្មាធិការរួម បានឯកភាពថានៅមានភាពខុសគ្នាក្នុងការយល់ឃើញពីប្រទេសនីមួយៗថាតើដំណើរការនៃកិច្ចពិគ្រោះយោបល់ជាមុន ត្រូវបញ្ចប់ រឺយ៉ាងណា ។

នៅក្នុងកិច្ចប្រជុំនេះ ប្រទេសឡាវទទួចថា មិនចាំបាច់ត្រូវមាន ការពន្យាពេលដំណើរការនោះឡើយ ដោយហេតុថាជំរើសនេះមិនសមស្របចំពោះការអនុវត្តជាក់ស្តែង នៅពេលដែលផលប៉ះពាល់បរិស្ថានឆ្លងដែនដល់ប្រទេសសមាជិកដ៏ទៃទៀតហាក់ដូចជាមិនមាន ។

ប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គដទៃទៀតដូចជា កម្ពុជា ថៃ និងវៀតណាមបានលើកឡើងពីកង្វល់របស់ខ្លួនចំពោះកង្វះខាតក្នុងចំណេះដឹងបច្ចេកទេស និងការសិក្សាអំពីគំរោងហើយបានប្រមើមើលពីផលប៉ះពាល់លើបរិស្ថាន និងការរស់នៅរបស់ប្រជាជនក្នុងអាងទន្លេមេគង្គ និងភាពចាំបាច់ដែលត្រូវមានការពិគ្រោះយោបល់ជាសាធារណៈបន្ថែមទៀត ។

លោក វីរ៉ាផុន វីរ៉ាវង្ស (Viraphonh Viravong) ប្រធានគណៈប្រតិភូឡាវបាននិយាយនៅក្នុងកិច្ចប្រជុំថា “យើងអរគុណាចំពោះយោបល់ទាំងអស់ ប៉ុន្តែយើងនឹងពិចារណាដើម្បីដោះស្រាយរាល់កង្វស់ទាំងអស់។ ”

ប្រទេសឡាវ ស្នើបញ្ចប់ដំណើរការនៃការពិគ្រោះយោបល់ជាមុន ដែលស្របនឹងចំណុច ៥.១ នៅក្នុងមាត្រា ៥ នៅក្នុងនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀងដែលចែងថា ពេលវេលាសំរាប់កិច្ចពិគ្រោះយោបល់ជាមុនមានរយៈពេល ៦ ខែគិតចាប់ពីថ្ងៃទទួលឯកសារស្តីពីការពិគ្រោះយោបល់ជាមុន និងចំណុច ៥.២ ដែលចែងថាប្រសិនបើមានការចាំបាច់ រយៈពេលដែលត្រូវពន្យាមួយនឹងត្រូវអនុញ្ញាតដោយសេចក្តីសំរេចរបស់គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គ ។

ប្រទេសឡាវ បានកត់សំគាល់ផងដែរថា ការពន្យាពេលដើម្បីធ្វើការសិក្សាបន្ថែមនឹងទាមទារពេលវេលាបន្ថែមលើសពី ៦ខែ ហើយនឹងមិនអាចដោះស្រាយរាល់កង្វល់របស់ភាគីទាំងអស់ដោយពេញចិត្តនោះទេ ។

លោក វីរ៉ាផុន វីរ៉ាវង្ស (Viraphonh Viravong) និយាយបន្ថែមថា គំរោងសាយ៉ាប៊ូរីនឹងស្របតាមគោលការណ៍ណែនាំបឋមសំរាប់ប្លង់ទំនប់វារីអគ្គិសនីរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេ

មេគង្គ (MRC Preliminary Design Guidance) និងការអនុវត្តថ្មីៗត្រឹមត្រូវផ្អែកលើ មាត្រដ្ឋានអន្តរជាតិ ។ គណៈប្រតិភូឡាវបានបន្ថែមទៀតថា ផលប៉ះពាល់ធ្ងន់ធ្ងរដល់នាវាចរ បំលាស់ទីរបស់ត្រី កករ គុណភាពទឹក និងអេកូឡូស៊ី និងសុវត្ថិភាពទំនប់អាច ត្រូវកាត់បន្ថយដល់កំរិតមួយដែលអាចទទួលយកបាន ។

ប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គដទៃទៀត បានសំដែងនូវកង្វល់ជាច្រើនចំពោះសំណើគំរោងសាយ៉ាប៊ូរី និងបានផ្តល់នូវអនុសាសន៏ខ្លះៗបន្ថែមទៀត ។

កម្ពុជា បាននិយាយថា ពេលវេលាបន្ថែមគួរតែចាំបាច់ដើម្បីអោយប្រទេសដែលត្រូវបានជូនដំណឹង និងអ្នកអភិវឌ្ឍន៏គំរោងបំពេញនូវកង្វះតំរូវការបច្ចេកទេស និងសំរាប់កិច្ចពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាពរវាងប្រទេសសមាជិក និងជាមួយសាធារណៈជន ។

កម្ពុជាបានបន្ថែមថា មានការចំបាច់សំរាប់ការសិក្សាស៊ីជម្រៅ និងទូលំទូលាយ និងការវាយតំលៃលើផលប៉ះពាល់បរិស្ថានឆ្លងដែន និងជាលំដាប់ (Cumulative impacts) ។ កម្ពុជាបន្ថែមថា ចាំបាច់ត្រូវបង្កើតវិធានការទប់ស្កាត់ និងដំណោះស្រាយដើម្បីកាត់បន្ថយផលប៉ះពាល់ក្នុងអំឡុងពេលដែលវិធានការណ៍ផ្សេងៗទៀតដូចជា ការបែងចែកផលចំណេញដល់ប្រទេសរងផលប៉ះពាល់ការគ្រប់គ្រងបរិស្ថានឆ្លងដែន និងមូលនិធីសង្គមត្រូវដាក់អោយអនុវត្តរួមគ្នា ។

គណៈប្រតិភូកម្ពុជា បានបញ្ជាក់ក្នុងចំលើយជាផ្លូវការរបស់ខ្លួនថា “ដោយសារពត៌មានអំពីគំរោងមិនទាន់គ្រប់គ្រាន់ កម្ពុជាបានស្នើអោយពន្យាពេលដំណើរការពិគ្រោះយោបល់ជាមុន។”

ប្រទេសថៃទទួលស្គាល់តួនាទីសំខាន់របស់គំរោងសាយ៉ាប៊ូរីនៅក្នុងផែនការអភិវឌ្ឍន៏របស់ប្រទេសឡាវ ហើយថៃបានឆ្លើយតបថា ដើម្បីដាក់អោយដំណើរការគំរោងបន្តទៅមុខទៀតចាំបាច់ត្រូវចាត់វិធានការដោះស្រាយប្រកបដោយការប្រុងប្រយ័ត្នជាមុន ដើម្បីជាផលប្រយោជន៏ ដល់ប្រជាជន និងបរិស្ថាននៅក្នុងតំបន់ ។

ប្រទេសថៃ បានលើកអំពីកង្វល់ដែលបានលើកឡើងក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីផលប៉ះពាល់លើបរិស្ថានដូចជា ការបាត់បង់ត្រី និងដីសំណើម និងកង្វះខាតវិធានការដោះស្រាយបញ្ហា

ច្បាស់លាស់ និងបាននិយាយថា ខ្លួនមានកង្វល់អំពីការរស់នៅរបស់ប្រជាជនដែលរស់នៅពឹងផ្អែកលើទន្លេមេគង្គ ។

ប្រទេសថៃ ក៏បានលើកឡើងផងដែរអំពីកង្វល់ពីវេទិការសាធារណៈអំពីនិរន្តភាពនៃគំរោងដែលនៅចោទជាសំនួរនៅឡើយ ហើយថាពេលវេលាកំណត់ដែលបានចែងសំរាប់ដំណើរការពិគ្រោះយោបល់ នៅមិនទាន់គ្រប់គ្រាន់ និងគួរតែធ្វើការពន្យាពេល ។

លោក ចាទុផន បូរុសផាត (Jatuporn Buruspat) អគ្គនាយកនាយកដ្ឋានធនធានទឹកថៃ បាននិយាយនៅក្នុងចំលើយជាផ្លូវការចំពោះគំរោងសាយ៉ាប៊ូរីថា "ហេតុដូច្នេះ យើងចង់ឃើញថាទស្សនៈ និងកង្វល់របស់សាធារណៈជនត្រូវបានទទួលការយកចិត្តទុកដាក់ និងពិចារណា" ។

ជាមួយគ្នានេះ វៀតណាមបានសំដែងកង្វល់យ៉ាងខ្លាំង និងស៊ីជំរៅចំពោះកង្វះខាតនៃការវាយតំលៃប្រកបដោយភាពត្រឹមត្រូវ សមរម្យ និងទូលំទូលាយនៃផលប៉ះពាល់ឆ្លងដែន និងជាលំដាប់ ដែលអាចបណ្តាលមកពីគំរោងដល់ផ្នែកខាងក្រោមទន្លេ ជាពិសេសដីសណ្តទន្លេមេគង្គ ។

វៀតណាមបានស្នើអោយមានការពន្យាពេលគំរោងនេះ និងគំរោងវារីអគ្គិសនីដទៃទៀតនៅលើទន្លេមេនៃទន្លេមេគង្គរយៈពេលយ៉ាងហោចណាស់ ១០ ឆ្នាំ ។

លោកបណ្ឌិត លីឌុច ជុង (Le Duc Trung) ប្រធានគណៈប្រតិភូវៀតណាម និយាយថា "ការពន្យាពេលគួរតែត្រូវបានមើលឃើញដោយវិជ្ជមានថា ជាមធ្យោបាយមួយដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់សំរាប់រដ្ឋាភិបាលប្រទេសសមាជិកធ្វើការសិក្សាអោយបានច្រើន និងទូលំទូលាយបន្ថែមទៀត លើផលប៉ះពាល់ជាលំដាប់ដែលកើតមាន" ។

វៀតណាមបន្ថែមទៀតថា ពេលវេលាកំណត់នៃដំណើរការពិគ្រោះយោបល់មិនគ្រប់គ្រាន់ដើម្បីសំរបសំរួលការសំរេចលើដំណើរការបានទេ ។ "ការពន្យាពេលនឹងផ្តល់អោយប្រទេសសមាជិក ធានាបាននូវការយល់កាន់តែច្បាស់ និងទំនុកចិត្តរបស់សាធារណៈជន និងសហគមន៍មូលដ្ឋាន" ។

សមាជិកគណៈកម្មាធិការចំរុះ នឹងធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំថ្ងៃនេះជូន

រដ្ឋមន្ត្រីនៃប្រទេសរៀងៗខ្លួន ។

**កំណត់សំគាល់បន្ថែមសំរាប់និពន្ធនាយកៈ**

កិច្ចព្រមព្រៀងមេគង្គរបស់គណៈកម្មការទន្លេមេគង្គឆ្នាំ ១៩៩៥ បានបង្កើតនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) ដែលបានថ្លែងថា ប្រទេសសមាជិកត្រូវជូនដំណឹងដល់គណៈកម្មាធិការរួមនៃគណៈកម្មការទន្លេមេគង្គក្នុងករណីប្រទេស នោះមានបំណងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធំៗណាមួយ ( ដូចជាគំរោងវារីអគ្គិសនី) នៅលើទន្លេមេនៃ ទន្លេមេគង្គ រឺនៅតាមដៃទន្លេមេគង្គ ជាពិសេសបើសិនការអភិវឌ្ឍនោះ អាចមានផលប៉ះពាល់ ឆ្លងដែនធំធេងលើប្រជាជន រឺបរិស្ថានផ្នែកខាងក្រោមទន្លេ ។

ដំណើរការនៃនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) គឺជាយន្តការផ្លូវការដើម្បីអនុញ្ញាតអោយប្រទេសសមាជិកមួយ រឺច្រើន លើកគំរោង ណាមួយ ដាក់ជូនសំរាប់ការពិចារណាថ្នាក់តំបន់ដោយប្រទេសសមាជិកទាំងបួន ។ ក្នុងករណីគំរោង វារីអគ្គិសនីសាយ៉ាបូរី រដ្ឋាភិបាលឡាវបានជូនដំណឹងដល់គណៈកម្មការទន្លេមេគង្គ ដើម្បីចាប់ផ្តើម ដំណើរការ ដំណើរការនៃនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) ។

គណៈកម្មការទន្លេមេគង្គ បានទទួលការជូនដំណឹងអំពីគំរោងអភិវឌ្ឍន៍វារីអគ្គីសនីសាយ៉ាបូរី ពីរដ្ឋភិបាលឡាវនៅខែ កញ្ញា ឆ្នាំមុន ។ ក្រោមដំណើរការនៃនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) ប្រទេសទាំងបួន ត្រូវពិភាក្សាគ្នា លើសំណើ ហើយបន្ទាប់មកនឹងធ្វើសេចក្តីសំរេចក្នុងរយៈពេល ៦ ខែ ចាប់តាំងពីការជូនដំណឹង ថាតើត្រូវដំណើរការគំរោងយ៉ាងដូចម្តេច ។

ចាប់តាំងពីការជូនដំណឹង ប្រទេសទាំងអស់ បានរៀបចំកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិជាមួយ អ្នកពាក់ព័ន្ធរួម ទាំងសហគមន៍ដែលអាចទទួលរងប៉ះពាល់ដើម្បីរបមូលទស្សនៈ និងទស្សនទានរបស់ ពួកគេអំពីគំរោងសាងសង់ ។ លេខាធិការគណៈកម្មការទន្លេមេគង្គ ក៏បានរៀបចំអោយ

ក្រុមជំនាញការផ្នែកបរិស្ថាន ដើម្បីធ្វើការពិនិត្យលើឯកសារជាច្រើនរួមមានទាំង របាយការណ៍អំពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលដាក់ជូនដោយរដ្ឋាភិបាលឡាវ ។

ដំណើរការពិគ្រោះយោបល់នេះ គឺជាពិធីសារមួយក្នុងចំណោមពិធីសារជាច្រើនក្នុងកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវធនធានទឹកអាងទន្លេ និងជៀសវាងការកើតឡើងនៃទំនាស់ក្នុងតំបន់ ។

គំរោងវារីអគ្គិសនីសាយ៉ាប៊ូរី ជាគំរោងទីមួយនៅលើទន្លេមេផ្នែកខាងក្រោមប្រទេសចិន ហើយមានសមត្ថភាពផលិតថាមពលអគ្គិសនីបានចំនួន ១២៦០ មេហ្គាវ៉ាត់ ដែលភាគច្រើននឹងត្រូវនាំចេញទៅប្រទេសថៃ ។

ទំនប់សាយ៉ាប៊ូរី ស្ថិតនៅចំងាយប្រមាណ ១៥០ គីឡូម៉ែតផ្នែកខាងក្រោមទីក្រុងហ្លួងប្រាបាង ប៉ែកខាងជើង ប្រទេសឡាវ ។ ទំនប់មានមានប្រវែង ៨១០ម៉ែត្រ មានកំពស់ ៣២ម៉ែត្រ និងទំហំអាងស្តុកទឹក ប្រវែង ៩៨ គីឡូម៉ែត្រការ៉េ ហើយស្តុកទឹកបានទំហំ ២២៥ លានម៉ែត្រគូប។ គោលដៅចំបងនៃទំនប់វារីអគ្គិសនីនេះ គឺដើម្បីបង្កើន ចំណូលរូបិយប័ណ្ណបរទេសសំរាប់ចំណាយលើការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងសង្គមនៅក្នុងប្រទេសឡាវ ។ ក្រុមហ៊ុនអភិវឌ្ឍន៍មានឈ្មោះ Ch. Karnchang Public Co. Ltd. របស់ប្រទេសថៃដែលបានចរចារអោយមានកិច្ចព្រមព្រៀងលើពន្ធនាំចូលជាមួយអាជ្ញាធរផលិតថាមពលអគ្គិសនីរបស់ប្រទេសថៃ (Electricity Generating Authority of Thailand, EGAT) កាលពីខែកក្កដា ឆ្នាំ ២០១០។

គណៈកម្មការទន្លេមេគង្គដើរតួនាទីជាអ្នកសំរបសំរួលដំនើរការ ដំណើរការនៃនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) ។ គណៈកម្មការទន្លេមេគង្គ ជាអង្គការអន្តររដ្ឋាភិបាលទទួលខុសត្រូវសំរាប់កិច្ចសហប្រតិបត្តិការលើការគ្រប់គ្រង ប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ ដោយមានប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាមជាសមាជិក ។ ប្រឈមមុខជាមួយបញ្ហានេះ គណៈកម្មការធ្វើសកម្មភាពលើគ្រប់វិស័យរួមមានធ្វើអោយមាននិរន្តភាពត្រី កំណាត់ឱកាសសំរាប់កសិកម្ម ថែរក្សាសេរីភាពនាវាចរគ្រប់គ្រងទឹកជំនន់ និងថែរក្សាប្រព័ន្ធអេកូឡូស៊ីដ៏សំខាន់ ។

កិច្ចប្រជុំពិសេសនៃគណៈកម្មការធិការរួមគណៈកម្មការទន្លេមេគង្គ ត្រូវបានរៀបចំក្នុងគោលបំណងស្វែងរកសេចក្តីសំរេចមួយអំពីដំណើរការនៃកិច្ចពិគ្រោះយោបល់ជាមុនលើគំរោងសាយ៉ាប៊ូរី ។ ប្រទេសដែលត្រូវបានជូនដំណឹងទាំង ៣ បានផ្តល់ចំលើយជាផ្លូវការចំពោះសំណើផលកិច្ចប្រជុំរួចហើយ ។


*សំរាប់ពត៏មានបន្ថែម សូមទាក់ទង:*

*លោក Surasak Glahan តាមរយ:ទូរស័ព្ទលេខ: ( ៨៥៦) ២០ ៥៥៥ ២៨៧២៦ រឺ អ៊ីម៉ែល:* surasak@mrcmekong.org

*លោកស្រី Tiffany Hacker តាមរយ:ទូរស័ព្ទលេខ: ( ៨៥៦) ២០ ៥៦១២ ០៦៩៥ រឺ អ៊ីម៉ែល:* tiffany@mrcmekong.org